**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ ០០៥.......សហវ

ថ្ងៃ ច័ន្ទ ៦រោច ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ២០១៨

# សេចក្ដីជូនដំណឹង
## ស្ដីពី
## ការប្រឡងប្រជែងជ្រើសរើសបេក្ខជនចូលបម្រើការងារនៅអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមជូនដំណឹងដល់បេក្ខជនសញ្ជាតិខ្មែរទាំងពីរភេទជាមន្ត្រីរាជការ ជានិស្សិត ពីវិស័យឯកជន និងសាធារណជនទូទៅ ឱ្យបានជ្រាបថា ក្រសួងនឹងធ្វើការប្រឡងប្រជែងជ្រើសរើសបេក្ខជនសញ្ជាតិខ្មែរទាំងពីរភេទ ចំនួន ៤៦៧ នាក់ (ប្រភេទក្របខ័ណ្ឌ "ក") ដើម្បីចូលបម្រើការងារនៅអគ្គនាយកដ្ឋានពន្ធដារ តាមតារាងបែងចែក និងលក្ខខណ្ឌកំណត់ដូចខាងក្រោម÷

| ល.រ | អង្គភាព | ចំនួន | ក្រប ខ័ណ្ឌ | ល.រ | អង្គភាព | ចំនួន | ក្រប ខ័ណ្ឌ |
|---|---|---|---|---|---|---|---|
| **នាយកដ្ឋានថ្នាក់កណ្ដាល** | | | | ២១ | សាខាពន្ធដារខេត្តបាត់ដំបង | ៨ | ក |
| ១ | នាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ | ២០ | ក | ២២ | សាខាពន្ធដារខេត្តកំពង់ចាម | ៨ | ក |
| ២ | នាយកដ្ឋានហិរញ្ញវត្ថុ និងបុគ្គលិក | ១៥ | ក | ២៣ | សាខាពន្ធដារខេត្តកំពង់ឆ្នាំង | ៥ | ក |
| ៣ | នាយកដ្ឋាននីតិកម្ម គោលនយោបាយសារពើពន្ធ និងសហប្រតិបត្តិការពន្ធអន្តរជាតិ | ២០ | ក | ២៤ | សាខាពន្ធដារខេត្តកំពង់ស្ពឺ | ៥ | ក |
| | | | | ២៥ | សាខាពន្ធដារខេត្តកំពង់ធំ | ៥ | ក |
| ៤ | នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន | ១៥ | ក | ២៦ | សាខាពន្ធដារខេត្តកំពត | ៥ | ក |
| ៥ | នាយកដ្ឋានស៊ើបអង្កេតបទល្មើសពន្ធដារ | ២៥ | ក | ២៧ | សាខាពន្ធដារខេត្តកណ្ដាល | ៨ | ក |
| ៦ | នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ | ៣៥ | ក | ២៨ | សាខាពន្ធដារខេត្តកោះកុង | ៥ | ក |
| ៧ | នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូច និងមធ្យម | ៤០ | ក | ២៩ | សាខាពន្ធដារខេត្តក្រចេះ | ៥ | ក |
| ៨ | នាយកដ្ឋានសវនកម្មសហគ្រាស | ៣០ | ក | ៣០ | សាខាពន្ធដារខេត្តមណ្ឌលគិរី | ៥ | ក |
| ៩ | សាលាជាតិពន្ធដារ | ២០ | ក | ៣១ | សាខាពន្ធដារខេត្តព្រះវិហារ | ៥ | ក |
| ១០ | ទីចាត់ការពន្ធដាររាជធានីភ្នំពេញ | ២០ | ក | ៣២ | សាខាពន្ធដារខេត្តព្រៃវែង | ៩ | ក |
| **សាខាពន្ធដារខណ្ឌ** | | | | ៣៣ | សាខាពន្ធដារខេត្តពោធិ៍សាត់ | ៥ | ក |
| ១១ | សាខាពន្ធដារខណ្ឌឫស្សីកែវ | ៨ | ក | ៣៤ | សាខាពន្ធដារខេត្តរតនគិរី | ៥ | ក |
| ១២ | សាខាពន្ធដារខណ្ឌដូនពេញ | ១០ | ក | ៣៥ | សាខាពន្ធដារខេត្តសៀមរាប | ១០ | ក |
| ១៣ | សាខាពន្ធដារខណ្ឌ៧មករា | ៩ | ក | ៣៦ | សាខាពន្ធដារខេត្តព្រះសីហនុ | ៦ | ក |
| ១៤ | សាខាពន្ធដារខណ្ឌមានជ័យ | ៩ | ក | ៣៧ | សាខាពន្ធដារខេត្តស្ទឹងត្រែង | ៥ | ក |
| ១៥ | សាខាពន្ធដារខណ្ឌចំការមន | ១៥ | ក | ៣៨ | សាខាពន្ធដារខេត្តស្វាយរៀង | ៥ | ក |
| ១៦ | សាខាពន្ធដារខណ្ឌទួលគោក | ៩ | ក | ៣៩ | សាខាពន្ធដារខេត្តតាកែវ | ៥ | ក |
| ១៧ | សាខាពន្ធដារខណ្ឌពោធិ៍សែនជ័យ | ៩ | ក | ៤០ | សាខាពន្ធដារខេត្តឧត្តរមានជ័យ | ៥ | ក |
| ១៨ | សាខាពន្ធដារខណ្ឌសែនសុខ | ៨ | ក | ៤១ | សាខាពន្ធដារខេត្តកែប | ៥ | ក |
| ១៩ | សាខាពន្ធដារខណ្ឌដង្កោ | ៨ | ក | ៤២ | សាខាពន្ធដារខេត្តប៉ៃលិន | ៥ | ក |
| **សាខាពន្ធដារខេត្ត** | | | | ៤៣ | សាខាពន្ធដារខេត្តត្បូងឃ្មុំ | ៥ | ក |
| ២០ | សាខាពន្ធដារខេត្តបន្ទាយមានជ័យ | ៨ | ក | | | | |
| Collection by VCAT Professional Consultant | | | | | **សរុប** | ៤៦៧ រូប | |



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92,Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax: 855-23-427 798

## ១. លក្ខខណ្ឌរួម

### ក. បេក្ខជនជានិស្សិត ពីវិស័យឯកជន និងសាធារណជនទូទៅ៖

- បេក្ខជនដែលមានកម្រិតបណ្តុះបណ្តាលចាប់ពីសញ្ញាបត្រថ្នាក់បណ្ឌិតឡើងទៅ ត្រូវបានលើកលែងលក្ខខណ្ឌអាយុ។
- បេក្ខជនដែលមានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ឬសមមូល ត្រូវមានអាយុច្រើនបំផុត ៤០ (សែសិប) ឆ្នាំ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨។
- បេក្ខជនដែលមានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រ ឬសមមូល ត្រូវមានអាយុច្រើនបំផុត ៣៥ (សាមសិបប្រាំ) ឆ្នាំ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨។

### ខ. បេក្ខជនជាមន្ត្រីរាជការ

- ត្រូវបានលើកលែងលក្ខខណ្ឌអាយុ។
- បេក្ខជនពីក្របខ័ណ្ឌមន្ត្រីរាជការនៃក្រសួង-ស្ថាប័ន នៃព្រះរាជាណាចក្រកម្ពុជា ត្រូវមានលិខិតបញ្ជាក់ទទួលស្គាល់ពីប្រធានក្រសួង-ស្ថាប័នសាមី ឬតំណាងដែលមានការប្រគល់សិទ្ធិ ជាមុនសិន ទើបមានសិទ្ធិចូលរួមក្នុងការប្រឡងប្រជែងនេះ។

### គ. កម្រិតបណ្តុះបណ្តាល

សញ្ញាបត្របរិញ្ញាបត្រ ឬសញ្ញាបត្រមានតម្លៃសមមូលឡើងទៅ លើមុខជំនាញ សេដ្ឋកិច្ច ហិរញ្ញវត្ថុ សវនកម្ម ធនាគារ ពាណិជ្ជសាស្ត្រ នីតិសាស្ត្រ (ជំនាញរដ្ឋបាលសាធារណៈ និងគោលនយោបាយសាធារណៈ...) និងរដ្ឋបាលធុរកិច្ច (ពន្ធដារ គណនេយ្យ ធនាគារ គ្រប់គ្រង និងទីផ្សារ ...) និងព័ត៌មានវិទ្យា។

## ២. វិញ្ញាសាប្រឡង

វិញ្ញាសាប្រឡង ជាវិញ្ញាសាសរសេរ រួមមាន: *(១).សេដ្ឋកិច្ច-ហិរញ្ញវត្ថុ (១០០ពិន្ទុ), (២).ពន្ធដារ (១០០ពិន្ទុ), (៣).គណនេយ្យ (១០០ពិន្ទុ) និង (៤).ភាសាអង់គ្លេស (៥០ពិន្ទុ)* ។

## ៣. ការបញ្ចប់ការសិក្សា

បេក្ខជនជានិស្សិត ពីវិស័យឯកជន និងសាធារណជនទូទៅ ត្រូវបញ្ចប់ថ្នាក់បរិញ្ញាបត្រយ៉ាងហោចណាស់ ចំនួន ០២ ឆ្នាំ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦។

## ៤. ការដាក់ពាក្យសុំចូលប្រឡង

បេក្ខជនទាំងពីរភេទ ត្រូវចូលទៅកាន់អាសយដ្ឋាន http://www.pd.mef.gov.kh ឬ http://www.tax.gov.kh ឬ http://www.efi.mef.gov.kh ដើម្បីបំពេញពាក្យស្នើសុំចុះឈ្មោះប្រឡងប្រជែងចូលបម្រើការងារ ហើយត្រូវបោះពុម្ពបង្កាន់ដៃដោយខ្លួនឯង បន្ទាប់មកត្រូវយកបង្កាន់ដៃនោះព្រមទាំងភ្ជាប់ជាមួយឯកសារពាក់ព័ន្ធដែលមានបញ្ជាក់ត្រឹមត្រូវ ចំនួន ០១ ច្បាប់ ដូចជា សញ្ញាបត្រ និងអត្តសញ្ញាណប័ណ្ណ ឬសៀវភៅគ្រួសារ ឬសំបុត្រកំណើត ឬសៀវភៅស្នាក់នៅ ***(បានបញ្ជាក់ត្រឹមត្រូវពីអាជ្ញាធរមានសមត្ថកិច្ច)***។ ដើម្បីប្រគល់ជូនមន្ត្រីទទួលពាក្យស្នើសុំ តាមកាលបរិច្ឆេទដែលគណៈកម្មការប្រឡងកំណត់ឱ្យមកបង្ហាញខ្លួន ស្កេនម្រាមដៃ និងថតរូប។

- **កាលបរិច្ឆេទចុះឈ្មោះ online:** ចាប់ពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៨ រហូតដល់ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៨ (៨:០០នាទី ដល់ ១៧:០០ នាទីរសៀល)។ ក្នុងករណី បេក្ខជនណាមួយពុំយល់ច្បាស់ពីនីតិវិធីនៃការចុះឈ្មោះ online បេក្ខជនអាចទំនាក់ទំនងមកមន្ត្រីនៅតាមទីកន្លែងទាំង ៣ ខាងក្រោម ដើម្បីទទួលបានព័ត៌មានបន្ថែម ចាប់ពីម៉ោង ៨:០០ នាទីព្រឹក ដល់ ១១:៣០ នាទីព្រឹក និងចាប់ពីម៉ោង ១៤:០០ នាទី ដល់ ១៧:៣០ នាទីរសៀល។
- **កាលបរិច្ឆេទនៃការបង្ហាញខ្លួន ស្កេនម្រាមដៃ និងថតរូប:** ចាប់ផ្តើមពីថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៨ ដល់ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៨ (៨:០០នាទី ដល់ ១១:៣០នាទីព្រឹក និង ១៤:០០នាទី ដល់ ១៧:០០នាទីរសៀល) នៅតាមទីកន្លែងដូចខាងក្រោម÷
    - នៅវិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាន់ទី ២ បន្ទប់លេខ ២២
    - នៅនាយកដ្ឋានបុគ្គលិក នៃអគ្គលេខាធិការដ្ឋាន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាគារ ខ បន្ទប់លេខ ២
    - នៅសាលាជាតិពន្ធដារ នៃអគ្គនាយកដ្ឋានពន្ធដារ ជាន់ទី១០។

Collection by VCAT Professional Consultant

*បញ្ជាក់៖ គណៈកម្មការប្រឡង ទទួលពាក្យស្នើសុំប្រឡងប្រជែងរបស់បេក្ខជនចូលបម្រើការងារនៅអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈ online តែប៉ុណ្ណោះ។*

ចំពោះកាលបរិច្ឆេទនៃការពិនិត្យឈ្មោះ និងផ្ទៀងផ្ទាត់ព័ត៌មានរបស់បេក្ខជនទាំងពីរភេទ បញ្ជីរាយនាមបេក្ខជនដែលមានសិទ្ធិចូលរួមការប្រឡងប្រជែង ពេលវេលាប្រឡង និងមណ្ឌលប្រឡង គណៈកម្មការរៀបចំការប្រឡងនឹងជូនដំណឹង និងបិទផ្សាយនៅនាយកដ្ឋានបុគ្គលិក នៃអគ្គលេខាធិការដ្ឋាន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅសាលាជាតិពន្ធដារ នៃអគ្គនាយកដ្ឋានពន្ធដារ និងនៅវិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬបេក្ខជនអាចទទួលព័ត៌មានតាមគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ www.tax.gov.kh ឬគេហទំព័រនាយកដ្ឋានបុគ្គលិក នៃអគ្គលេខាធិការដ្ឋាន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ www.pd.mef.gov.kh ឬក៏គេហទំព័រវិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ www.efi.mef.gov.kh។

*សម្រាប់ព័ត៌មានលំអិត សូមទំនាក់ទំនងតាមលេខទូរស័ព្ទ៖*

| នាយកដ្ឋានបុគ្គលិក | អគ្គនាយកដ្ឋានពន្ធដារ | វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
|---|---|---|
| ០១២ ៥៣៦ ៤១៦ | ០៩៩ ៧៦៩ ៤៧៦ | ០១០ ២៨៤ ៧៨២ |
| ០១៧ ៥១០ ១១៣ | ០៧០ ៧៧ ៥៤ ៩៣ | ០១១ ៨៨៧ ៧៨៩ |

**រដ្ឋលេខាធិការ**

**ប្រធានគណៈកម្មការប្រឡង**

**បណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប**

**ចម្លងជូន៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ *"ដើម្បីជូនជ្រាប"*
- អគ្គនាយកដ្ឋានពន្ធដារ *"ដើម្បីចាត់ចែងផ្សព្វផ្សាយ"*
- វិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- នាយកដ្ឋានបុគ្គលិក នៃអគ្គលេខាធិការ កសហវ
- ឯកសារ-កាលប្បវត្តិ

Collection by VCAT Professional Consultant